**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ២៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការបង្កើតវិទ្យាស្ថានក្រុងអង្គរ

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញលិខិតស្នើសុំរបស់ លោក ហុក សឿន ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០១
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

**មាត្រា ១ :** អនុញ្ញាតអោយបង្កើត គ្រឹះស្ថានឧត្តមសិក្សា ឯកជនមួយ ដែលមានឈ្មោះថា **វិទ្យាស្ថានក្រុងអង្គរ** **(Angkor City Institute)** ហៅកាត់ជាភាសាខ្មែរ "វកអ" និងហៅកាត់ជាភាសាអង់គ្លេស "ACI" ។

www.pheakdeylaw.com

វិទ្យាស្ថាននេះ ស្ថិតនៅក្រោមឱវាទ របស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំង នៅអាគារ លេខ ២៣២ ភូមិវិហារចិន ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា ២ :** វិទ្យាស្ថានក្រុងអង្គរ ធ្វើការបណ្តុះបណ្តាល ថ្នាក់បរិញ្ញាប័ត្រ ដែលមានរយៈពេលសិក្សាយ៉ាងតិច ៤ ឆ្នាំ ត្រូវនឹង ៣២០០ ម៉ោង ជាមធ្យម ។

**មាត្រា ៣ :** វិទ្យាស្ថានក្រុងអង្គរ មានមហាវិទ្យាល័យ :

- មហាវិទ្យាល័យគ្រប់គ្រងពាណិជ្ជកម្ម និង ទេសចរណ៍
- មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច
- មហាវិទ្យាល័យពត៌មានវិទ្យា

ទៅអនាគត វិទ្យាស្ថាននេះ អាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេសជំនាញ ដ៏ទៃទៀត ដោយរៀបចំសំណុំបែបបទ សុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** វិទ្យាស្ថានក្រុងអង្គរ មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារ ពិនិត្យ និង សំរេច លើគោល នយោបាយ និង ផែនការអភិវឌ្ឍរបស់វិទ្យាស្ថាន និងមានក្រុមប្រឹក្សាវិទ្យាសាស្ត្រមួយសំរាប់ ពិនិត្យ លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** នាយកវិទ្យាស្ថានក្រុងអង្គរ មានភារកិច្ច :

- ជ្រើសរើសនិស្សិតអោយចូលរៀន និងជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិកបំរើការងារ ។
- គ្រប់គ្រងអោយបានល្អនូវ ការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំ របស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៦ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថានក្រុងអង្គរ និង បានទទួលជោគជ័យ ក្នុងការប្រលង បញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រ ដែលផ្តល់អោយ ដោយវិទ្យាស្ថានក្រុងអង្គរ ហើយ ត្រូវបានទទួលស្គាល់ ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី វិទ្យាស្ថាននេះបានបំពេញ និង អនុវត្ត តាមគោលការណ៍ របស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង វិទ្យាស្ថានក្រុងអង្គរ មានភារកិច្ចរៀង ១ ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាម អនុក្រឹត្យនេះ ។

www.pheakdeylaw.com

**មាត្រា ៨ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ភ្នំពេញ ថ្ងៃទី០៨ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាខេត្តសៀមរាប

  " ដើម្បីមុខការ "
- ដូចមាត្រា ៧ "ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ

www.pheakdeylaw.com